# សាមគ្គីភាពដើម្បីសន្តិភាព និងវិបុលភាពរួម៖
# ពង្រឹងច្បាប់អន្តរជាតិ និងដោះស្រាយជម្លោះដោយសន្តិវិធី

## សន្និសីទប្រធានសភានៃអន្តរសភាលើកទី២ (ISC-2)

## ថ្ងៃទី ២៦-២៨ ខែសីហា ឆ្នាំ ២០២៦ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសទីក្រុងភ្នំពេញ

**យើងខ្ញុំជាប្រធានសភា និងតំណាងសភាមកពីតំបន់ផ្សេងៗជុំវិញពិភពលោក ជួបជុំគ្នានៅក្នុងសន្និសីទប្រធានសភានៃអន្តរសភាលើកទី២ (ISC-2) នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៦,**

**ពិចារណាឃើញថា** សហគមន៍អន្តរជាតិនៅតែបន្តប្រឈមមុខនឹងបញ្ហាប្រឈមដ៏ស្មុគស្មាញជាច្រើន រួមមាន ជម្លោះ ភាពតានតឹងភូមិសាស្ត្រនយោបាយ ភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច ការរំខានដល់លំហូរពាណិជ្ជកម្ម ការប្រែប្រួលអាកាសធាតុ អសន្តិសុខស្បៀង និងថាមពល ការរំខានផ្នែកបច្ចេកវិទ្យា និងការគំរាមកំហែងតាមប្រព័ន្ធបច្ចេកវិទ្យា វិបត្តិមនុស្សធម៌ និងវិសមភាពដែលកំពុងតែរីកធំឡើង;

**បញ្ជាក់ជាថ្មី** នូវការប្តេជ្ញាចិត្តរបស់យើងចំពោះអធិបតេយ្យ បូរណភាពទឹកដី ឯករាជ្យភាពនយោបាយ ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋនីមួយៗ និងការដោះស្រាយវិវាទដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ រួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ ដោយភាពពេញលេញ និងភាពប្រទាក់ក្រឡាគ្នា;

**រំលឹក** អំពីតួនាទីដែលមិនអាចខ្វះបានរបស់សភា ក្នុងការលើកកម្ពស់កិច្ចសន្ទនា ការទូតសភា សន្តិភាព សន្តិសុខ ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលការណ៍ប្រជាធិបតេយ្យក្នុងទំនាក់ទំនងអន្តរជាតិ;

**រំលឹកផងដែរ** នូវសេចក្តីសម្រេច និងគំនិតផ្តួចផ្តើមពាក់ព័ន្ធនានារបស់អង្គការអន្តរសភា ដែលបានបញ្ជាក់ជាថ្មីអំពីការគោរពអធិបតេយ្យ និងបូរណភាពទឹកដីរបស់រដ្ឋ និងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទដោយសន្តិវិធី តាមរយៈកិច្ចសន្ទនា និងស្របតាមច្បាប់អន្តរជាតិ;

**កោតសរសើរ** ព្រះរាជាណាចក្រកម្ពុជា ចំពោះការទទួលធ្វើជាម្ចាស់ផ្ទះប្រកបដោយជោគជ័យនៃសន្និសីទប្រធានសភានៃអន្តរសភាលើកទី២;

សូមប្រកាសដូចខាងក្រោម៖

## I. ចក្ខុវិស័យរួមរបស់យើង

យើងខ្ញុំ បញ្ជាក់ជាថ្មីនូវបំណងប្រាថ្នារួមរបស់យើង សម្រាប់សណ្តាប់ធ្នាប់ពិភពលោកមួយប្រកបដោយសន្តិភាព និងយុត្តិធម៌ ដែលផ្អែកលើច្បាប់អន្តរជាតិ សមភាពអធិបតេយ្យ សន្តិភាព និងសន្តិសុខ កិច្ចសហប្រតិបត្តិការពហុភាគីនិយម និងការអភិវឌ្ឍប្រកបដោយចីរភាព។

## II. សន្តិភាព ច្បាប់អន្តរជាតិ និងការទូតសភា

យើងខ្ញុំ ប្តេជ្ញាចិត្ត៖

- គោរពប្រតិបត្តិតាមច្បាប់អន្តរជាតិ រួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ និងលើកកម្ពស់ការគោរពកាតព្វកិច្ចនៃច្បាប់អន្តរជាតិ;
- គាំទ្រការដោះស្រាយវិវាទដោយសន្តិវិធី តាមរយៈកិច្ចសន្ទនា ការពិគ្រោះយោបល់ ការចរចាការសម្រុះសម្រួល និងមធ្យោបាយសន្តិវិធីផ្សេងទៀត ស្របតាមច្បាប់អន្តរជាតិរួមទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ;
- ពង្រឹងពហុភាគីនិយម ជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់សន្តិភាព សន្តិសុខ ស្ថិរភាព ការអភិវឌ្ឍ និងវិបុលភាពជាអន្តរជាតិ;
- ពង្រឹងការទូតសភា ជាឧបករណ៍ដ៏សំខាន់សម្រាប់ការកសាងទំនុកចិត្ត ការបង្ការជម្លោះ កិច្ចសន្ទនា ការផ្សះផ្សា និងកិច្ចសហប្រតិបត្តិការអន្តរជាតិ រួមទាំងតាមរយៈការគាំទ្រការលើកកម្ពស់ការទូតបង្ការជម្លោះ និងវិធានការសន្តិវិធីផ្សេងទៀត ដែលជួយដោះស្រាយភាពតានតឹងមុនពេលបញ្ហាក្លាយទៅជាជម្លោះ;
- លើកកម្ពស់កិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធរវាងសភានានា ក្នុងការដោះស្រាយបញ្ហាប្រឈមរួមនៅថ្នាក់តំបន់ និងសកល។

## III. ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិសុខមនុស្ស

ដោយទទួលស្គាល់ថា សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពពង្រឹងនិងគាំទ្រគ្នាទៅវិញទៅមក យើងខ្ញុំបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសភា ដើម្បីលើកកម្ពស់៖

- ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងចីរភាព;
- សន្តិសុខស្បៀង ថាមពល និងសុខភាព ព្រមទាំងការគ្រប់គ្រងធនធានទឹកប្រកបដោយចីរភាព;
- ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាពបរិស្ថាន;

- ខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយសុវត្ថិភាព និងចីរភាព ព្រមទាំងសេរីភាពនៃការធ្វើនាវាចរណ៍តាមមធ្យោបាយដឹកជញ្ជូនគ្រប់ទម្រង់ ស្របតាមច្បាប់អន្តរជាតិ ដើម្បីធានាបាននូវស្ថិរភាពសេដ្ឋកិច្ច;
- បរិវត្តកម្មឌីជីថលប្រកបដោយការទទួលខុសត្រូវ និងនវានុវត្តន៍ផ្នែកបច្ចេកវិទ្យា;
- ការអប់រំ ការផ្លាស់ប្តូរវប្បធម៌ និងកិច្ចសន្ទនាពហុជំនឿសាសនា;
- ការពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## IV. **មាគ៌ាឆ្ពោះទៅមុខ**

យើងខ្ញុំ សម្រេចចិត្តបន្តពង្រឹងសន្និសីទប្រធានសភានៃអន្តរសភា តាមរយៈ៖

- ការពង្រឹងកិច្ចសន្ទនា កិច្ចសហប្រតិបត្តិការ ភាពជាដៃគូ និងការផ្លាស់ប្តូររវាងសភាដែលចូលរួម;
- ការលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍ផ្នែកនីតិកម្ម ចំណេះដឹង និងឧត្តមានុវត្តន៍;
- ការគាំទ្រការកសាងសមត្ថភាព និងការចូលរួមរបស់សភាប្រកបដោយបរិយាបន្ន ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ;
- ការធ្វើឱ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនង ការសម្របសម្រួល និងការតាមដានលទ្ធផលនៃកិច្ចពិភាក្សា និងគំនិតផ្តួចផ្តើមរបស់ ISC រួមទាំងតាមរយៈការផ្លាស់ប្តូរបទពិសោធន៍ និងឧត្តមានុវត្តន៍រវាងសភាដែលចូលរួម។

## V. **ការអភិវឌ្ឍនាពេលអនាគតរបស់** ISC

យើងខ្ញុំ គាំទ្រការបន្ត ការពង្រីក ប្រសិទ្ធភាព និងចីរភាពរយៈពេលវែងនៃសន្និសីទប្រធានសភានៃអន្តរសភា។ ក្នុងន័យនេះ យើងខ្ញុំ លើកទឹកចិត្តឱ្យសភាដែលចូលរួម លេខាធិការដ្ឋាន ISC និងសមាជិកស្ថាបនិករបស់ ISC បន្តការពិគ្រោះយោបល់ ដើម្បីទទួលស្វាគមន៍សភាចំនួនកាន់តែច្រើន និងរៀបចំយន្តការដែលមានលក្ខណៈជាក់ស្តែង បរិយាបន្ន បត់បែនបាន និងព្រមព្រៀងគ្នាទៅវិញទៅមក ដើម្បីពង្រឹងបន្ថែមនូវនិរន្តរភាពស្ថាប័ន ការសម្របសម្រួលប្រតិបត្តិការ ការទទួលស្គាល់នៃតួនាទីស្នូល និងការអភិវឌ្ឍរយៈពេលវែងរបស់ ISC។

យើងខ្ញុំ សូមស្វាគមន៍ និងថ្លែងអំណរគុណសាធារណរដ្ឋឥណ្ឌូណេស៊ី ក្នុងការធ្វើជាម្ចាស់ផ្ទះនៃសន្និសីទប្រធានសភា នៃអន្តរសភាលើកទី៣ (ISC-3) នៅឆ្នាំ២០២៧ និងសូមបង្ហាញការគាំទ្រយ៉ាងពេញទំហឹងរបស់យើងចំពោះ **សភាជាន់ខ្ពស់នៃសាធារណរដ្ឋឥណ្ឌូណេស៊ី** ក្នុងការបន្តជំរុញវឌ្ឍនភាពនិងសមិទ្ធផលដែលបានបង្កើតឡើងតាមរយៈសន្និសីទនេះ។

## VI. ការប្តេជ្ញាចិត្តចុងក្រោយ

យើងខ្ញុំ បញ្ជាក់ជាថ្មីថា កិច្ចសហប្រតិបត្តិការអន្តរជាតិ និងពហុភាគីនិយម នៅតែជាមូលដ្ឋានដែលមិនអាចខ្វះបានសម្រាប់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ដោយការរួបរួមគ្នាប្រកបដោយដោយការទទួលខុសត្រូវរបស់យើង ដើម្បីទទួលបានពិភពលោកមួយដែលមានចីរភាព យុត្តិធម៌ និងសមធម៌កាន់តែប្រសើរ សម្រាប់មនុស្សជំនាន់នេះ និងអនាគត យើងខ្ញុំប្តេជ្ញាបន្តធ្វើការរួមគ្នា ដើម្បីគោរព និងលើកកម្ពស់ការដោះស្រាយវិវាទដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ពង្រឹងការទូតសភា និងចូលរួមចំណែកកសាងពិភពលោកមួយប្រកបដោយសន្តិភាព បរិយាបន្ន យុត្តិធម៌ និងវិបុលភាពកាន់តែប្រសើរ។

**បានអនុម័តនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៦**